ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ២៣១៥ ព.ណ.សន.ច

ថ្ងៃ ... ខែ ... ឆ្នាំ ... ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹង

## ស្តីពីការដាក់ឲ្យអនុវត្តវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញអេឡិកត្រូនិកទម្រង់ D (e-Form D) ក្រោមក្របខ័ណ្ឌតំបន់ពាណិជ្ជកម្មសេរីអាស៊ាន និងវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ E ថ្មី ក្រោមក្របខ័ណ្ឌតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន

យោងស្មារតីកិច្ចប្រជុំលើកទី៤៧ របស់ក្រុមការងារបច្ចេកទេសបញ្ជរតែមួយអាស៊ានលើកទី៤៧ (47th ASEAN Single Window Technical Working Group) នៅប្រទេសសិង្ហបុរី កាលពីថ្ងៃទី០៧-១០ ខែឧសភា ឆ្នាំ២០១៩ និង កិច្ចប្រជុំគណៈកម្មការចម្រុះតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិនលើកទី១២ ស្តីពីវិធានប្រភពដើមទំនិញ(ACFTA-JC WG-ROO) នៅទីក្រុងបាងកក ប្រទេសថៃ កាលពីថ្ងៃទី២០-២២ ខែឧសភា ឆ្នាំ២០១៩ ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជន អ្នកនាំចេញ និងផលិតករពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបថា៖ ក្រសួងពាណិជ្ជកម្ម នឹងដាក់ឲ្យអនុវត្តការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញអេឡិកត្រូនិកទម្រង់ D (e-Form D) ជូន សម្រាប់ការនាំចេញទំនិញទៅកាន់ទីផ្សារអាស៊ាន **ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ តទៅ**។ ក្នុងកំឡុងពេលអន្តរកាលសាកល្បងប្រព័ន្ធថ្មីនេះ ក្រសួងពាណិជ្ជកម្មនៅបន្តចេញសន្លឹកវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ D អមជាមួយ។

ជាមួយគ្នានេះដែរ ក្រសួងពាណិជ្ជកម្មចាប់ផ្តើមដាក់ឲ្យអនុវត្តពេញលេញនូវ ទម្រង់ E ថ្មី (New Form E) វិធានដើមកំណើតទំនិញថ្មី (New ROO) វិធានប្រតិបត្តិនៃការចេញវិញ្ញាបនបត្រថ្មី (New OCP) និង វិធានសម្រាប់ផលិតផលជាក់លាក់ (ATTACHMENT B) ក្នុងប្រព័ន្ធសុខដុម HS 2017 ក្រោមក្របខ័ណ្ឌតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន តាមរយៈការស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទម្រង់ E ទៅកាន់ទីផ្សារអាស៊ាន-ចិន **ចាប់ពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ តទៅ**។ ដូចនេះក្នុងកំឡុងពេលអន្តរកាលចាប់ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ រហូតដល់ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ប្រទេសជាសមាជិកអាចអនុវត្ត ទម្រង់ E ចាស់ជាមួយវិធានចាស់; ឬ ទម្រង់ E ថ្មីជាមួយវិធានថ្មី។ ចំពោះប្រទេស ដែលអនុវត្ត HS 2017 នាំចេញទៅកាន់ប្រទេសម៉ាឡេស៊ី ត្រូវដាក់បង្ហាញ HS 2012 អមជាមួយ។

សូមចូលទៅកាន់គេហទំព័រក្រសួងពាណិជ្ជកម្ម https://co.moc.gov.kh ដើម្បីទទួលបានឯកសារខាងលើជា Soft Copy។ ចំពោះព័ត៌មានបន្ថែម សូមទំនាក់ទំនងមន្ត្រីនៃនាយកដ្ឋាននាំចេញ-នាំចូល ៖

១-លោក ស៊ី បាទិត្យ អនុប្រធាននាយកដ្ឋាន ទូរស័ព្ទ៖ ០១២ ៩៤៨ ៤៨៤ សារអេឡិកត្រូនិក៖ batithsy@yahoo.com

២-លោក ស្វាយ សុផល ប្រធានការិយាល័យ ទូរស័ព្ទ៖ ០១១ ៧៥៧ ១៦៥ សារអេឡិកត្រូនិក៖ sophal.svay@yahoo.com

៣-លោក សោម សុទ្ធា មន្ត្រី ទូរស័ព្ទ៖ ០៧០ ៦០៦ ០០៤ សារអេឡិកត្រូនិក៖ somsothea@gmail.com

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន អ្នកនាំចេញ និងផលិតករពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឲ្យមានប្រសិទ្ធភាពដោយស្មារតីទទួលខុសត្រូវខ្ពស់។

សូមអរគុណ!

ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469